# មន្ទីរកសិកម្មខេត្តកណ្តាល

# ត្រប់




**អាស័យដ្ឋានទំនាក់ទំនង: ផ្លូវលេខ ១០៣ (តាខ្មៅ)**

**ទំនាក់ទំនងទូរស័ព្ទ: (០២៣ ៩៨៣ ៤៦១)**

**(០១២ ៨២៤ ៤២៥)**



**ឧបត្ថម្ភដោយ: អង្គការទីទីអូប៊ី VVOB**

vvob education for development

**ឆ្នាំ ២០១០**


# ដំណាំត្រប់

## ១-ស្ថានភាពទូទៅ

នៅប្រទេសកម្ពុជា ត្រប់ជាប្រភេទបន្លែមួយយ៉ាងសាម័ញ្ញ ដែលប្រជាជនគ្រប់គ្នាតែងតែប្រើប្រាស់ធ្វើជាបន្លែក្នុងជីវភាពប្រចាំថ្ងៃ។ គេអាចដាំដុះវាជាលក្ខណៈចំការធំៗ និងជាលក្ខណៈសួនបន្លែចំរុះនៅតាមគ្រួសារ។

## ២. បច្ចេកទេសដាំដុះ

### រដូវកាលដាំដុះ

-រដូវប្រាំង: គេចាប់ផ្តើមសាបកូននៅខែតុលា ហើយដាំខែវិច្ឆិកា ប្រមូលផលខែមករា ដល់ ខែមិនា។

-រដូវវស្សា: គេអាចសាបនៅខែឧសភា និងដាំនៅខែមិថុនា ប្រមូលផលនៅខែសីហា និង ខែតុលា ពិសេសតំបន់ខ្ពង់រាប។

### ការជ្រើសរើសពូជ

- ពូជមានប្រភពច្បាស់លាស់ (ពូជបង្កាត់ Hybrid $F_1$ ឬពូជក្នុងស្រុក )
- ពូជធន់នឹងជំងឺ សត្វល្អិត
- គ្រាប់ពូជត្រូវមានសុខភាពល្អ
- មានអាយុកាលលូតលាស់ខ្លី
- សមស្របតាមតំបន់ដាំដុះ និងតំរូវការទីផ្សារ
- មានដំណុះចាប់ពី ៨៥-៩០%
- ចំនួនពូជប្រើក្នុង១ហិកតាពី ១៥០-២០០ក្រាម។

### ការរៀបចំដី

ត្រូវរាស់ប្រមូលស្មៅ កាកសំណល់ដំណាំចាស់ៗយកទៅដុត ឬយកចេញពីចំការ បន្ទាប់មកភ្ជួរហាលដីរយៈពេលពី ៥-៧ថ្ងៃ ដើម្បីឱ្យស្មៅងាប់ និងផ្តាច់ជីវិតពពួកសត្វល្អិតចង្រៃផ្សេងៗនៅក្នុងដី។ ក្រោយមកទើបរាស់បំបែកដីឱ្យម៉ត់ និងកៀរដីអោយស្មើពី ៣-៤លើក និងលើករងកំពស់ ២៥-៣០ សង្ទីម៉ែត្រទទឹងរង ១២០ សង្ទីម៉ែត្រ បណ្តោយរងតាមផ្ទៃដីជាក់ស្តែង ។

### ការដាំដុះ

ក-ការសាបគ្រាប់: គ្រាប់ត្រប់តូចល្អិត សំប៉ែត សំបករឹងហើយក្រាស់ មុននឹងសាបគ្រាប់ពូជត្រូវយកមកសំអាតជាមុនសិន បន្ទាប់មកយកទៅហាលថ្ងៃរយៈពេល ១ ទៅ ២ ម៉ោង ក្រោយមកទៀត ត្រូវយកទៅត្រាំទឹកក្តៅអ៊ុនៗ (ត្រាំគ្រាប់ពូជនៅក្នុងទឹកក្តៅ ៥០អង្សាសេ ដោយលាយទឹកក្តៅ ១ ទឹកត្រជាក់២) រយៈពេល ១៥-២០នាទី ។ រួចទើបទៅត្រាំទឹកត្រជាក់ធម្មតា ១យប់ បន្ទាប់មកយកទៅផ្អាប់ ២យប់ នៅពេលគ្រាប់ត្រប់ដុះពន្លកសៗ ដំបូងអាចយកទៅសាប ឬ ដាក់ក្នុងកន្ទោងបានហើយ ។

របៀបសាបគ្រាប់លើថ្នាលធម្មតា: ដំបូងត្រូវរកទីតាំងថ្នាលសាបគឺ ដីស្រឡះ ដីទួលស្រស់ទឹក មានជីជាតិល្អ បន្ទាប់មកត្រូវកាប់ហាលដីអោយស្ងួត ទើបលើករងអោយបានត្រឹមត្រូវ ដីលើករងត្រូវធ្វើយ៉ាងណាឱ្យម៉ត់ល្អកៀរ និងរាបស្មើទើបយកជីកំប៉ុស្តិ៍ក្នុងបរិមាណ ១៥តោន/ហិចតា បន្ទាប់មករាស់លប់ជីទាំងនោះអោយកប់ជ្រៅទៅក្នុងដី ។